ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : 660 PEAC.អក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្គត់ផ្គង់ម៉ាស៊ីនថ្លឹងនាឡិកាស្ទង់មួយហ្វាចំនួនមួយគ្រឿង

## ជូនអគ្គិសនីស្វាយរៀង

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/ សហគ្រាស(គិតទាំងសហគ្រាស ឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បី ផ្គត់ផ្គង់ម៉ាស៊ីនថ្លឹងនាឡិកាស្ទង់មួយហ្វាចំនួនមួយគ្រឿង ជូនអគ្គិសនីស្វាយរៀង ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន / សហគ្រាសបំពេញ ដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាស័យដ្ឋានៈ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ : 023 67 66 007 និង Website : (www.edc.com.kh ) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ១១:00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើវេលាម៉ោង ១៥:00 នាទី ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និង សាកសួរពត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី 17 ខែ 05 ឆ្នាំ ២០១៦

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**គឹម_អ៊ីង**

ចម្លងជូន :

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ